## ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ ..........០៩៧/១៤........ក.ប/ប្រ.ក

# ប្រកាស
## ស្តីពី
## ការបង្កើតលេខាធិការដ្ឋានរបស់គណៈកម្មការប្រឹក្សាការងារ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៦ ស្តីពីសមាភាព និងការប្រព្រឹត្តទៅនៃគណៈកម្មការប្រឹក្សាការងារ
- បានឃើញប្រកាសលេខ ០៦៨/១៤ ក.ប/ប្រក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៣ ស្តីពីការផ្លាស់ប្តូរសមាសភាពសមាជិកគណៈកម្មការប្រឹក្សាការងារ អាណត្តិទី៨
- យោងតាមការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតលេខាធិការដ្ឋានរបស់គណៈកម្មការប្រឹក្សាការងារ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **សាត សមុទ្រ** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២-ឯកឧត្តម | **ហេង សួរ** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣-ឯកឧត្តម | **សេង សក្ដា** | អគ្គនាយកការងារ | អនុប្រធាន |
| ៤- ឯកឧត្តម | **ទេស រុក្ខាផល** | អគ្គលេខាធិការរង អ.គ.ក.ប | សមាជិក |
| ៥-ឯកឧត្តម | **ហុង ជឿន** | ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ | សមាជិក |
| ៦-លោក | **គឹម ចំរើន** | ទីប្រឹក្សាអមក្រសួង | សមាជិក |
| ៧-លោក | **អ៊ិន ខេមរា** | ប្រធាននាយកដ្ឋានអធិការកិច្ចការងារ | សមាជិក |



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

| | | | |
|---|---|---|---|
| ៨-លោក | **ភុយ ទេពដារាវុធ** | ប្រធាននាយកដ្ឋានវិវាទការងារ | សមាជិកអចិន្ត្រៃយ៍ |
| ៩-លោក | **ប៉ុល ចាន់ដារ៉ា** | អនុប្រធាននាយកដ្ឋានអធិការកិច្ចការងារ | សមាជិក |
| ១០-លោក | **ហួន សឿរ** | អនុប្រធាននាយកដ្ឋានវិវាទការងារ | សមាជិក |
| ១១-លោក | **ខៀវ សាវុធ** | អនុប្រធាននាយកដ្ឋានវិវាទការងារ | សមាជិក |
| ១២-លោក | **ខេង សំបូរ** | អនុប្រធាននាយកដ្ឋានវិវាទការងារ | សមាជិក |
| ១៣-លោក | **ជ្រុន ថេរ៉ាវង្ស** | អនុប្រធាននាយកដ្ឋានវិវាទការងារ | សមាជិក |
| ១៤-លោក | **ស្រ៊ុន ចន្ថុល** | អនុប្រធាននាយកដ្ឋានអធិការកិច្ចការងារ | សមាជិក |
| ១៥-លោក | **និន វណ្ណៈ** | អនុប្រធានន.ផែនការ ស្ថិតិនិងនីតិកម្ម | សមាជិក |
| ១៦-លោក | **ជា ស៊ាងហុង** | ប្រធានការិយាល័យវិវាទការងារទី៣ | សមាជិក |
| ១៧-លោក | **ហោង ម៉ុនថា** | ប្រធានការិយាល័យទំនាក់ទំនងវិជ្ជាជីវៈ | សមាជិក |
| ១៨-លោក | **លេង ម៉ុនណារ៉ា** | មន្ត្រីទីភ្នាក់ងារជាតិមុខរបរ និងការងារ | សមាជិក |

លេខាធិការដ្ឋាននេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួល ក្នុងកិច្ចការសិក្សាស្រាវជ្រាវអំពីបញ្ហាប្រាក់ឈ្នួលអប្បបរមាសមស្របសម្រាប់កម្មករនិយោជិត។
- លើកផែនការថវិកាសម្រាប់អនុវត្តការងាររបស់គណៈកម្មការ។
- ទំនាក់ទំនង និងសហប្រតិបត្តិការជាមួយដៃគូសង្គម និងដៃគូអភិវឌ្ឍន៍នានា។
- សម្របសម្រួលជាមួយអង្គការអន្តរជាតិខាងការងារ លើការងារជំនួយបច្ចេកទេស។
- រៀបចំ និងចាត់ចែងរាល់កិច្ចប្រជុំពាក់ព័ន្ធនានា។
- ធ្វើកំណត់ហេតុ និងរបាយការណ៍របស់កិច្ចប្រជុំនានា។
- បំពេញភារកិច្ចផ្សេងៗទៀតតាមការចាត់តាំងរបស់ប្រធានគណៈកម្មការ។

**ប្រការ ២.-**

ក្នុងករណីប្រធានអវត្តមាន អនុប្រធានអាចដឹកនាំជំនួសតាមការប្រគល់ភារកិច្ចរបស់ប្រធាន។

**ប្រការ ៣.-**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៤.-**

នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋានការងារ ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ ប្រធាននាយកដ្ឋានអធិការកិច្ចការងារ ប្រធាននាយកដ្ឋានវិវាទការងារ និងសាមីខ្លួនមានភារកិច្ចអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ប្រការ ៥.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**<u>ចម្លងជូន៖</u>**

-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯ.ឧឧបនាយករដ្ឋមន្ត្រី ស ខេង
-ខុទ្ទកាល័យឯ.ឧ គាត ឈន់ ឧបនាយករដ្ឋមន្ត្រីប្រចាំការ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
-គ្រប់សមាគមនិយោជក
-គ្រប់សហព័ន្ធសហជីព
"ដើម្បីជូនជ្រាប"
-ឯកសារ - កាលប្បវត្តិ